**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខ: ០០៦ មស. ក្រ.ខ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១០

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** : ការធ្វើផែនការក្របខ័ណ្ឌ-ថវិកា មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែតសំរាប់ឆ្នាំ ២០១១ ។

**យោង** : សារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា ដើម្បីមានមូលដ្ឋានក្នុងការបូកសរុបផែនការក្របខ័ណ្ឌសំរាប់ឆ្នាំ ២០១១ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមស្នើឯកឧត្តមមេត្តាលើកសំណើអំពីសេចក្តីត្រូវការប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែតសំរាប់ ឆ្នាំ ២០១១ ផ្ញើមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈឱ្យបានមុន ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ទោះបីពុំមានសុំបន្ថែមក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និង ពលករអណ្តែតក៏ដោយ បើហួសរយៈពេលនេះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈពុំទទួលខុសត្រូវឡើយ ។

សំណុំលិខិតដែលត្រូវបំពេញរួមមាន :

| | |
|---|---|
| ១- លិខិតស្នើសុំប្រើប្រាស់ក្របខ័ណ្ឌ សំរាប់ ឆ្នាំ ២០១១ | ២ ច្បាប់ |
| ២- តារាងគំរោងក្របខ័ណ្ឌ សំរាប់ ឆ្នាំ ២០១១ | ២ ច្បាប់ |
| ៣- តារាងស្នើសុំជ្រើសរើសបុគ្គលិកថ្មី សំរាប់ ឆ្នាំ ២០១១ | ២ ច្បាប់ |
| ៤- ឯកសារផ្សេងៗដែលពាក់ព័ន្ធ | ២ ច្បាប់ |

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ពេជ្រ ប៊ុនធិន

ចម្លងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ឯកសារ-កាលប្បវត្តិ